ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ០៧ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# លក្ខន្តិកៈសមាជិកបណ្ឌិតសភានៃរាជបណ្ឌិត្យសភាកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- ព្រះរាជក្រមលេខ នស/រកម/០៦១៣/០១២ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីវិសោធនកម្មមាត្រា២៨នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១១១ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៥ ស្តីពីការកែសម្រួលមាត្រា៤ មាត្រា១០ មាត្រា១១ មាត្រា១២ មាត្រា១៤ មាត្រា១៧ និងមាត្រា២០ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧១៧/៥៨៦ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៧ ស្ដីពីការកែសម្រួលមាត្រា៦ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្ដីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា និងមាត្រា៤ថ្មី, មាត្រា១០ថ្មី, មាត្រា១១ថ្មី, មាត្រា១២ថ្មី និងមាត្រា២០ថ្មី នៃព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១១១ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៥ ស្ដីពីការកែសម្រួលមាត្រា៤ មាត្រា១០, មាត្រា១១, មាត្រា១២, មាត្រា១៤, មាត្រា១៧ និងមាត្រា២០ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្ដីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៧/៥៩២ ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៧ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៧/៣១០ ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៧ ស្ដីពីប្រាក់បំណាច់ស្រាវជ្រាវរបស់សមាជិកបណ្ឌិតសភា និងមន្ត្រីស្រាវជ្រាវនៃរាជបណ្ឌិត្យសភាកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៤៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០០ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់រាជបណ្ឌិត្យសភាកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីស្ដីទីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី

## សម្រេច

## ជំពូកទី ១
## បទបញ្ញត្តិទូទៅ

**មាត្រា១**.-

អនុក្រឹត្យនេះមានគោលបំណងកំណត់លក្ខន្តិកៈសមាជិកបណ្ឌិតសភានៃរាជបណ្ឌិត្យសភាកម្ពុជា។

**មាត្រា២**.-

អនុក្រឹត្យនេះមានគោលដៅកំណត់ពីលក្ខណៈសម្បត្តិ ការទទួលខុសត្រូវ និងសិទ្ធិរបស់សមាជិកបណ្ឌិតសភា នៃរាជបណ្ឌិត្យសភាកម្ពុជា។

**មាត្រា៣**.-

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះសមាជិកបណ្ឌិតសភានៃរាជបណ្ឌិត្យសភាកម្ពុជា។

## ជំពូកទី ២
## ប្រភេទ លក្ខខណ្ឌ និងលក្ខណៈសម្បត្តិនៃសមាជិកបណ្ឌិតសភា

**មាត្រា៤**.-

សមាជិកបណ្ឌិតសភានៃរាជបណ្ឌិត្យសភាកម្ពុជា មានបីប្រភេទ៖

- សមាជិកពេញសិទ្ធិ
- សមាជិកបម្រុង

- សមាជិកសមាគមិក និងសមាជិកកិត្តិយស។

**មាត្រា៥.-**

សមាជិកពេញសិទ្ធិនៃរាជបណ្ឌិត្យសភាកម្ពុជា មានគោរមងារជាបណ្ឌិតសភាចារ្យ។

សមាជិកពេញសិទ្ធិ អាចត្រូវបានជ្រើសរើសពីក្នុងចំណោមសមាជិកបម្រុងនៃរាជបណ្ឌិត្យសភាកម្ពុជា ដែលបានចូលជាសមាជិកបម្រុងយ៉ាងតិចពីរឆ្នាំ មានស្នាដៃស្រាវជ្រាវវិទ្យាសាស្ត្របន្តក្រោយពេលចូលជាសមាជិកបម្រុងយ៉ាងតិចចំនួនពីរស្នាដៃដែលទទួលស្គាល់ដោយក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ និងមានទំនាក់ទំនងល្អក្នុងរាជបណ្ឌិត្យសភាកម្ពុជា។

ប្រធានក្រុមប្រឹក្សាបណ្ឌិតសភាចារ្យអាចលើកសំណើជូននាយករដ្ឋមន្ត្រី ពិនិត្យ និងសម្រេច ជាករណីពិសេស ក្នុងការបញ្ចូលជាសមាជិកពេញសិទ្ធិនៃរាជបណ្ឌិត្យសភាកម្ពុជានូវៈ

- សមាជិកបម្រុងនៃរាជបណ្ឌិត្យសភាកម្ពុជា
- បញ្ញាជនមានសញ្ញាបត្រថ្នាក់បណ្ឌិតដែលសម្រេចបាននូវការរកឃើញថ្មីក្នុងវិស័យស្រាវជ្រាវវិទ្យាសាស្ត្រ ឬដែលសម្រេចបាននូវស្នាដៃនវានុវត្តបច្ចេកទេស ឬបច្ចេកវិទ្យាដែលផ្តល់គុណប្រយោជន៍ធំធេងដល់សង្គមជាតិ និង
- ឥស្សរជនដែលមានសញ្ញាបត្រថ្នាក់បណ្ឌិត ហើយមានបទពិសោធការងារយ៉ាងតិច ១០ឆ្នាំ ក្រោយទទួលបានសញ្ញាបត្រថ្នាក់បណ្ឌិត និងមានគុណសម្បត្តិធំធេងក្នុងកិច្ចការរៀបចំ និងដឹកនាំអនុវត្តគោលនយោបាយអភិវឌ្ឍន៍សង្គមជាតិដែលការបញ្ចូលតាមករណីពិសេសនៃចំណុចនេះ មានចំនួនយ៉ាងច្រើនស្មើនឹងមួយភាគបីនៃចំនួនសមាជិកពេញសិទ្ធិសរុប ៧៩រូប ដូចមានកំណត់នៅក្នុងព្រះរាជក្រឹត្យលេខ នស/រកត/០៧១៧/៥៨៦ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៧។

បេក្ខជនដែលត្រូវបានជ្រើសចូលជាសមាជិកពេញសិទ្ធិ ត្រូវមានសុចរិតភាព ប្រវត្តិការងារល្អ មានសីលធម៌រស់នៅល្អ និងមិនដែលមានទោសឧក្រិដ្ឋ ឬមជ្ឈិម។

**មាត្រា៦.-**

សមាជិកពេញសិទ្ធិនៃរាជបណ្ឌិត្យសភាកម្ពុជាមានចំនួនកំណត់មិនលើសពី ៧៩រូប។

ចំនួនសមាជិកពេញសិទ្ធិនៃរាជបណ្ឌិត្យសភាកម្ពុជា ត្រូវមានប្រហាក់ប្រហែលគ្នារវាងអ្នកវិទ្យាសាស្ត្រសង្គម និងវិទ្យាសាស្ត្រពិត ឬត្រូវកំណត់ដោយយោងតាមតម្រូវការចាំបាច់ជាក់ស្តែងរបស់ប្រទេសជាតិ។

**មាត្រា៧.-**

សមាជិកបម្រុង ត្រូវជ្រើសរើសដោយក្រុមប្រឹក្សាបណ្ឌិតសភាចារ្យក្នុងចំណោមបុគ្គលដែលបានបំពេញលក្ខខណ្ឌ ដូចខាងក្រោមៈ

១- បានដាក់ពាក្យសុំចូលជាសមាជិកបម្រុង។

២- មានសញ្ញាបត្រថ្នាក់បណ្ឌិត។

៣- បាន និងកំពុងបំពេញការងារក្នុងក្របខ័ណ្ឌការងារឯកទេសរបស់ខ្លួនយ៉ាងតិច ១០ឆ្នាំ ក្រោយពេលទទួលបានសញ្ញាបត្រថ្នាក់បណ្ឌិត។

៤- បានបោះពុម្ពផ្សាយស្នាដៃស្រាវជ្រាវវិទ្យាសាស្ត្រសង្គម ឬវិទ្យាសាស្ត្រពិតជាសាធារណៈយ៉ាងតិច ៣ ដែលទទួលស្គាល់ដោយក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ។

៥- មានសុចរិតភាព ប្រវត្តិការងារល្អ និងមានសីលធម៌រស់នៅល្អ។

៦- មិនដែលមានទោសឧក្រិដ្ឋ ឬមជ្ឈឹម។

**មាត្រា៨.-**

សមាជិកសមាគមិក និងសមាជិកកិត្តិយស ត្រូវជ្រើសរើសពីក្នុងចំណោមជនជាតិខ្មែរ និងជនជាតិបរទេសដែលបានជួយឧបត្ថម្ភចំពោះការពង្រីកវិទ្យាសាស្ត្រសង្គម និងវិទ្យាសាស្ត្រពិត ជាគុណប្រយោជន៍ដល់ប្រទេសកម្ពុជា ដោយក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ និងតាមសំណើពីសមាជិកពេញសិទ្ធិណាម្នាក់ ឬពីសាមីខ្លួនដោយមានការធានាពីសមាជិកពេញសិទ្ធិយ៉ាងតិចចំនួន ៣រូប។

សមាជិកសមាគមិក ត្រូវជ្រើសរើសក្នុងចំណោមអ្នកមានសញ្ញាបត្រថ្នាក់បណ្ឌិត។

សមាជិកកិត្តិយស ត្រូវជ្រើសរើសពីមជ្ឈដ្ឋានអ្នកមានកិត្តិនាមល្បីល្បាញ។

សមាជិកសមាគមិក និងសមាជិកកិត្តិយស មានចំនួនតាមការចាំបាច់។

សមាជិកសមាគមិក និងសមាជិកកិត្តិយសត្រូវមានសុចរិតភាព ប្រវត្តិការងារល្អ មានសីលធម៌រស់នៅល្អ និងមិនដែលមានទោសឧក្រិដ្ឋ ឬមជ្ឈឹម។

**មាត្រា៩.-**

បែបបទនិងនីតិវិធីនៃការប្រជុំ មហាសន្និបាតនៃក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ ការដាក់ពាក្យស្នើសុំការបោះឆ្នោតជ្រើសរើស និងការតែងតាំងសមាជិកពេញសិទ្ធិ សមាជិកបម្រុង សមាជិកសមាគមិក និងសមាជិកកិត្តិយស ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ។

**មាត្រា១០.-**

សមាជិកពេញសិទ្ធិ មានគោរមងារជាបណ្ឌិតសភាចារ្យ ដែលត្រូវតែងតាំងដោយព្រះរាជក្រឹត្យ។

សមាជិកបម្រុង សមាជិកសមាគមិក និងសមាជិកកិត្តិយស ត្រូវតែងតាំងដោយអនុក្រឹត្យ។

**មាត្រា១១.-**

សមាជិកភាពនៃសមាជិកពេញសិទ្ធិ សមាជិកបម្រុង សមាជិកសមាគមិក និងសមាជិកកិត្តិយសនៃរាជបណ្ឌិត្យសភាកម្ពុជាត្រូវរលាយបាត់វិញដោយមរណភាព ការសុំលាឈប់ ឬត្រូវតុលាការផ្តន្ទាទោសពីបទល្មើសណាមួយ។

## ជំពូកទី ៣
## មហាសន្និបាត ការប្រជុំ និងជំនួបវិទ្យាសាស្ត្រ

**មាត្រា១២.-**

សមាជិកបណ្ឌិតសភានៃរាជបណ្ឌិត្យសភាកម្ពុជាត្រូវចូលរួមមហាសន្និបាតសាមញ្ញ និងវិសាមញ្ញ ប្រជុំសាមញ្ញប្រចាំឆមាស និងប្រជុំវិសាមញ្ញ តាមការអញ្ជើញរបស់ប្រធានក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ ដើម្បីពិនិត្យនិងសម្រេចលើករណីដូចខាងក្រោម៖

- សំណើកំណត់ក្របខ័ណ្ឌគោរមងារនៃរាជបណ្ឌិត្យសភាកម្ពុជា
- សំណើផ្តល់គោរមងារនៃរាជបណ្ឌិត្យសភាកម្ពុជា ជូនឥស្សរជននានា

- ផែនការយុទ្ធសាស្ត្ររយៈពេលវែង និងមធ្យម ដែលស្នើឡើងដោយរាជបណ្ឌិត្យសភាកម្ពុជាដើម្បីតម្រង់ទិសនៃការសិក្សាស្រាវជ្រាវ និងការអភិវឌ្ឍវិទ្យាសាស្ត្រ
- កម្មវិធី និងលទ្ធផលនៃការប្រកួតប្រជែងស្នាដៃស្រាវជ្រាវវិទ្យាសាស្ត្រ និងនវានុវត្តន៍ក្នុងវិស័យផ្សេងៗមានជាអាទិ៍ វប្បធម៌ សិល្បៈ អក្សរសាស្ត្រ ទស្សនវិជ្ជា សង្គមកិច្ច សេដ្ឋកិច្ច បច្ចេកវិទ្យា សហគ្រិនភាព និងឧស្សាហកម្ម
- ការផ្ដល់ពានរង្វាន់ដល់ស្នាដៃស្រាវជ្រាវវិទ្យាសាស្ត្រ និងនវានុវត្តន៍ក្នុងវិស័យផ្សេងៗមានជាអាទិ៍ វប្បធម៌ សិល្បៈ អក្សរសាស្ត្រ ទស្សនវិជ្ជា សង្គមកិច្ច សេដ្ឋកិច្ច បច្ចេកវិទ្យា សហគ្រិនភាព និងឧស្សាហកម្ម
- ការបោះឆ្នោតជ្រើសរើសសមាជិកពេញសិទ្ធិ សមាជិកបម្រុង សមាជិកសមាគមិក និងសមាជិកកិត្តិយសនៃរាជបណ្ឌិត្យសភាកម្ពុជា
- ពិនិត្យ និងសម្រេចករណីផ្សេងៗទៀតតាមការកំណត់របស់ក្រុមប្រឹក្សាបណ្ឌិតសភាចារ្យតាមការចាំបាច់។

**មាត្រា១៣.-**

កូរ៉ុមប្រជុំដែលចាត់ទុកបានការនិងអាចប្រជុំបាន លុះត្រាតែមានសមាជិកពេញសិទ្ធិចំនួនភាគច្រើនដាច់ខាតនៃចំនួនសមាជិកពេញសិទ្ធិ។ សេចក្ដីសម្រេចត្រូវយកតាមសម្លេងភាគច្រើននៃចំនួនអ្នកវត្តមាន។ បើមានសម្លេងស្មើគ្នា សម្លេងប្រធានមានឧត្តមានុភាព។

**មាត្រា១៤.-**

រាល់ការប្រជុំរបស់ក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ សមាជិកបម្រុងអាចចូលរួមតាមការអញ្ជើញរបស់ប្រធានក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ និងមានសិទ្ធិផ្ដល់យោបល់ ប៉ុន្តែពុំមានសិទ្ធិក្នុងការបោះឆ្នោតសម្រេចទៅលើកិច្ចការណាមួយឡើយ។

**មាត្រា១៥.-**

សមាជិកបណ្ឌិតសភានៃរាជបណ្ឌិត្យសភាកម្ពុជា ត្រូវចូលរួមក្នុងជំនួបវិទ្យាសាស្ត្រដែលរៀបចំដោយរាជបណ្ឌិត្យសភាកម្ពុជា។

## ជំពូកទី៤
## ភារកិច្ច និងការទទួលខុសត្រូវរបស់សមាជិកបណ្ឌិតសភា

**មាត្រា១៦.-**

សមាជិកពេញសិទ្ធិ និងសមាជិកបម្រុង មានភារកិច្ច និងការទទួលខុសត្រូវនៅក្រោមក្របខណ្ឌសមត្ថកិច្ចនៃរាជបណ្ឌិត្យសភាកម្ពុជាដូចខាងក្រោម៖

១- សិក្សា និងរៀបចំគោលនយោបាយស្រាវជ្រាវជាតិ ។

២- រៀបចំគម្រោងផែនការអភិវឌ្ឍការងារស្រាវជ្រាវវិទ្យាសាស្ត្រសង្គម ឬវិទ្យាសាស្ត្រពិត។

៣- ផ្ដួចផ្ដើមនិងបង្កើតស្នាដៃស្រាវជ្រាវវិទ្យាសាស្ត្រសង្គម ឬវិទ្យាសាស្ត្រពិត។

៤- ផ្ដល់យោបល់ជំនាញលើស្នាដៃស្រាវជ្រាវរបស់មន្ត្រីស្រាវជ្រាវ។

៥- ទទួលខុសត្រូវចំពោះលទ្ធផលស្រាវជ្រាវតាមក្រមសីលធម៌វិជ្ជាជីវៈ។

៦- ធ្វើកិច្ចសហប្រតិបត្តិការក្នុងការស្រាវជ្រាវវិទ្យាសាស្ត្រសង្គម ឬវិទ្យាសាស្ត្រពិត ជាមួយស្ថាប័នជាតិ និងអន្តរជាតិ។

ភារកិច្ច និងការទទួលខុសត្រូវទាំងនេះ ជាលក្ខខណ្ឌសម្រាប់អតីតភាពវិទ្យាសាស្ត្រក្នុងសមាជិកភាពពេញសិទ្ធិ និងសមាជិកភាពបម្រុង។

សមាជិកសមាគមិក និងសមាជិកកិត្តិយស ត្រូវរួមចំណែកដល់ការងារស្រាវជ្រាវ វប្បធម៌ និងវិទ្យាសាស្ត្រ ព្រមទាំងអាចជួយឧបត្ថម្ភគាំទ្រដល់ការអភិវឌ្ឍរាជបណ្ឌិត្យសភាកម្ពុជា។

## ជំពូកទី ៥
## បុព្វសិទ្ធិរបស់សមាជិកបណ្ឌិតសភា

**មាត្រា១៧.-**

សមាជិកពេញសិទ្ធិ និងសមាជិកបម្រុង មានឯករាជ្យក្នុងការស្រាវជ្រាវវិទ្យាសាស្ត្រតាមជំនាញរៀងៗខ្លួន ដោយប្រកាន់នូវក្រមសីលធម៌វិជ្ជាជីវៈ។

ការបំពេញមុខងារស្រាវជ្រាវរបស់សមាជិកពេញសិទ្ធិ និងសមាជិកបម្រុង ជាបុគ្គល ឬជាក្រុម ត្រូវធ្វើឡើង ដោយមានផែនការច្បាស់លាស់ និងមានការឯកភាពពីរាជបណ្ឌិត្យសភាកម្ពុជា។

លទ្ធផលនៃការស្រាវជ្រាវរបស់សមាជិកពេញសិទ្ធិ និងសមាជិកបម្រុង ដែលស្ថិតក្នុងផែនការរបស់រាជបណ្ឌិត្យសភាកម្ពុជា ជាកម្មសិទ្ធិរបស់រដ្ឋ ប៉ុន្តែសមាជិកនោះអាចទទួលបាននូវកម្រៃកម្មសិទ្ធិបញ្ញាពីស្នាដៃរបស់ខ្លួនតាមការកំណត់របស់រាជរដ្ឋាភិបាល ។

សមាជិកពេញសិទ្ធិ និងសមាជិកបម្រុងត្រូវធ្វើរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការងារស្រាវជ្រាវរបស់ខ្លួនមកជូនរាជបណ្ឌិត្យសភាកម្ពុជានៅពាក់កណ្តាលគម្រោង និងចុងបញ្ចប់នៃគម្រោងស្រាវជ្រាវ។

**មាត្រា១៨.-**

ការស្រាវជ្រាវត្រូវបានទទួលការគាំពារពីរដ្ឋក្នុងការការពារកម្មសិទ្ធិបញ្ញា ការបោះពុម្ពផ្សាយ ការចូលទៅកាន់ទីកន្លែងដែលជាកម្មវត្ថុនៃការស្រាវជ្រាវ ការការពារផ្នែកសន្តិសុខ និងសុវត្ថិភាពនៅទីកន្លែងជាកម្មវត្ថុនៃការស្រាវជ្រាវ និងការផ្តល់ធនធានសម្រាប់ការស្រាវជ្រាវ។

**មាត្រា១៩.-**

សមាជិកពេញសិទ្ធិ និងសមាជិកបម្រុង ត្រូវទទួលប្រាក់បំណាច់ស្រាវជ្រាវ ប្រាក់ស្រាវជ្រាវប្រចាំឆ្នាំ ប្រាក់សុខភាព និងប្រាក់បំណាច់ផ្សេងៗទៀត ដែលត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែក។

**មាត្រា២០.-**

សមាជិកពេញសិទ្ធិ ទទួលបាននូវគោរមងារជាបណ្ឌិតសភាចារ្យ និងទទួលបាននូវបុព្វសិទ្ធិដូចមានចែងក្នុងមាត្រា១៩ខាងលើ រហូតអស់មួយជីវិត លើកលែងតែការសុំលាឈប់ ឬត្រូវផ្តន្ទាទោស ដូចក្នុងមាត្រា១១ នៃអនុក្រឹត្យនេះ។

## ជំពូកទី ៦
## អវសានប្បញ្ញត្តិ

**មាត្រា២១.-**

អនុក្រឹត្យលេខ១៧២ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧ ស្តីពីលក្ខន្តិកៈសមាជិកបណ្ឌិតសភានៃរាជបណ្ឌិត្យសភាកម្ពុជា និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា២២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ ប្រធានរាជបណ្ឌិត្យសភាកម្ពុជា រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ៦ កើត ខែ មាឃ ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ មករា ឆ្នាំ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីស្តីទី**
**ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**ប៊ិន ឈិន**

**<u>កន្លែងទទួល</u>** :
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា ២២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ